# តារាងព័ត៌មានស្តីពីតំបន់បណ្តាញផ្លូវហោះហើរ
# កំណត់ចំណាំសម្រាប់អ្នកចង្ក្រង

អង្គភាពគ្រប់គ្រងចង់ដាក់បញ្ចូលតំបន់មួយ ទៅក្នុងបណ្តាញផ្លូវហោះហើរអូស្ត្រាលី-អាស៊ីខាងកើត គឺត្រូវគេស្នើឲ្យបំពេញតារាងព័ត៌មានមួយ ។ តារាងព័ត៌មាននឹងផ្តល់ព័ត៌មានដូលដ្ឋាន ស្តីពីតំបន់ និងព័ត៌មានលំអិតបញ្ជាក់អំពីតំបន់ដែលបំពេញនូវលក្ខណៈវិនិច្ឆ័យ សម្រាប់បញ្ចូលតំបន់នោះទៅក្នុងបណ្តាញផ្លូវហោះហើរ ។

តារាងព័ត៌មានតំបន់ត្រូវបែងចែកជាពីរផ្នែក ។ ភាគទី១(ផ្នែកទី១-១៤) ស្វែងរកព័ត៌មានមូលដ្ឋានស្តីពីតំបន់ និងសារៈសំខាន់របស់វាដែលត្រូវបំពេញ ។ ភាគទី២ ស្វែងរកព័ត៌មានបន្ថែមទៀត និងអាចជ្រើសរើសបាន ។

តារាងព័ត៌មានតំបន់ គឺផ្អែកលើតារាងព័ត៌មានរ៉ាមសារ ។ ប្រសិនបើតំបន់ត្រូវបានស្នើបញ្ចូលជាបណ្តាញតំបន់ផ្លូវហោះហើរ គឺជាតំបន់រ៉ាមសារស្រាប់ គណៈនេះ ដំណើរការឯកសារអាចធ្វើបានយ៉ាងងាយស្រួល ។ ករណីនេះ ដៃគូរដ្ឋាភិបាលជាតិតម្រូវឲ្យផ្ញើតែច្បាប់ចម្លង នៃតារាងព័ត៌មានដែលមានស្រាប់ ដោយភ្ជាប់ជាមួយនឹងព័ត៌មានលំអិតបបន្ថែមទៀត នៅក្នុងសំណួរទី១ និងសំណួរទី១០ នៃតារាងព័ត៌មានស្តីពីតំបន់ផ្លូវហោះហើរ ។

នៅពេលបំពេញតារាងព័ត៌មានចប់សព្វគ្រប់ (និងភ្ជាប់ជាមួយផែនទី)គួរត្រូវដាក់ស្នើទៅលេខាធិការដ្ឋានភាពជាដៃគូផ្លូវហោះហើរ ។ អ្នកចង្ក្រងគួរផ្តល់ច្បាប់ចម្លងអេឡិចត្រូនិចនៃតារាងព័ត៌មាន ហើយបើអាចច្បាប់ចម្លងឌីជីថលនៃផែនទីទាំងអស់ ។

## ភាគ ១: ព័ត៌មានសំខាន់ៗ

**១. ឈ្មោះ និងអាស័យដ្ឋានលំអិតរបស់អ្នកចង្ក្រងឯកសារនេះ**

ឈ្មោះពេញ ស្ថាប័ន/ទីភ្នាក់ងារ និងអាស័យដ្ឋានរបស់អ្នកចង្ក្រងតារាងព័ត៌មាន ដោយមានលេខទូរសព្ទ/លេខទូរសារ និងអាស័យដ្ឋានអ៊ីមែល

**២.កាលបរិច្ឆេទដែលតារាងព័ត៌មានត្រូវបានបំពេញ**

កាលបរិច្ឆេទដែលតារាងព័ត៌មានត្រូវបានបំពេញ ឬធ្វើឲ្យទាន់ហេតុការណ៍

**៣. ប្រទេស**

ឈ្មោះប្រទេសជាផ្លូវការ ដែលកែប្រែចុងក្រោយ(ខ្លី)

**៤. ឈ្មោះ នៃបណ្តាញតំបន់ផ្លូវហោះហើរ**

ឈ្មោះតំបន់ដែលបានកំណត់ច្បាស់លាស់ជាភាសាជាតិ និងអង់គ្លេស ។ ឈ្មោះនេះនឹងត្រូវប្រើប្រាស់យ៉ាងត្រឹមត្រូវ ដូចនៅក្នុងការផ្តល់វិញ្ញាបនបត្រទទួលស្គាល់តំបន់ ។ ឈ្មោះផ្សេងទៀតជាភាសាក្នុងស្រុក គួរត្រូវផ្តល់ឲ្យដោយដាក់ក្នុងវង្ងង់ក្រចក បន្ទាប់ពីឈ្មោះដាក់លាក់ ។

**៥. ផែនទីតំបន់**

ផែនទីសមស្រប និងថ្មីៗបំផុត គួរត្រូវភ្ជាប់ជាមួយតារាងព័ត៌មានទាំងនោះ ហើយបើអាច ផែនទីទម្រង់ជាអេឡិចត្រូនិច ។ ផែនទីត្រូវបង្ហាញព្រំប្រទល់តំបន់ឲ្យបានច្បាស់លាស់ ។

**៦. កូអរដោណេភូមិសាស្ត្រ (រយៈទទឹង និងរយៈបណ្តោយ ជាដឺក្រេ)**

ផ្តល់កូអរដោណេនៃចំណុចកណ្តាលតំបន់ និងឬ ការកម្រិត នៃតំបន់ ។ ប្រសិនបើ តំបន់កើតឡើងដោយតំបន់ច្រើនជាងមួយ ត្រូវផ្តល់កូអរដោណេតំបន់នីមួយ នៃតំបន់ទាំងនោះ ។

**៧. កម្រិតកំពស់** (ជាម៉ែត្រ: មធ្យម និងឬ អតិបរមា និងអប្បបរមា)

**៨. ផ្ទៃក្រឡាតំបន់**

ផ្ទៃក្រឡាសរុប គឺជា ហិកតា ។ ប្រសិនបើ ផ្ទៃក្រឡានៃផ្នែកផ្សេងគ្នា នៃតំបន់ត្រូវបានគេស្គាល់ សូមចុះបញ្ជីផ្នែកតំបន់ទាំងនោះជាមួយគ្នា ដោយរួមទាំងឈ្មោះ(ឬស្លាក)ដែលប្រើប្រាស់ ដើម្បីកំណត់ និងធ្វើឲ្យផ្សេងគ្នានូវផ្នែកទាំងនោះ។

**៩. ការពិនិត្យទូទៅនៃតំបន់**

ការរៀបរាប់សង្ខេបនៃតំបន់ (កំណត់មិនឲ្យលើស ២ ប្រយោគ) រៀបរាប់អំពីសារៈសំខាន់រូបសាស្ត្រ តួនាទីអេកូឡូស៊ី និងសារៈសំខាន់របស់វាសម្រាប់សត្វស្លាបទឹកទេសន្តរប្រវេសន៍ ។

**១០. ការផ្ទៀងផ្ទាត់នៃលក្ខណៈវិនិច្ឆ័យសម្រាប់បណ្តាញតំបន់ផ្លូវហោះហើរ៖**

សូមផ្តល់ព័ត៌មានស្តីពីការរាប់សត្វស្លាបទឹក ដែលផ្តោតលើតំបន់ដែលបំពេញតាមលក្ខណៈវិនិច្ឆ័យនៃបណ្តាញតំបន់ផ្លូវហោះហើរ (ឧបសម្ព័ន្ធ១) ។ នោះគឺ៖

- វាទ្រទ្រង់ជាទៀងទាត់ សត្វស្លាបទឹកដែលធ្វើទេសន្តរប្រវេសន៍ ចំនួនជាង ២០.០០០ ក្បាល
- វាទ្រទ្រង់ជាទៀងទាត់ ច្រើនជាង១%នៃសត្វស្លាបទឹកនៅក្នុងចំនួនសត្វស្លាបសរុប នៃប្រភេទនីមួយៗ ឬ អនុប្រភេទ នៃសត្វស្លាបទឹកដែលធ្វើទេសន្តរប្រវេសន៍ ឬ
- វាទ្រទ្រង់ចំនួនច្រើនគួរសម នៃប្រភេទជិតផុតពូជ ឬ ចំនួនសត្វស្លាបទឹកដែលងាយរងគ្រោះ ឬ
- វាគឺជា "តំបន់សំចត" ទ្រទ្រង់សត្វស្លាបទឹកច្រើនជាង ៥.០០០ ឬ ច្រើនជាង ០,២៥%នៃចំនួនសរុបដែលបង្កើតបាននៅក្នុងតំបន់ ។

បញ្ជីចំនួនសត្វស្លាបទឹកដែលធ្វើទេសន្តរប្រវេសន៍ដែលគ្រប់ដណ្តប់ដោយភាពជាដៃគូផ្លូវហោះហើរអូស្ត្រាលី-អាស៊ីខាងកើត និងកម្រិតស្តង់ដា ១% គឺត្រូវភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ៣ ។

"តំបន់សំចត" លក្ខណៈវិនិច្ឆ័យ គឺលំបាកណាស់ក្នុងការអនុវត្ត និងការអនុវត្តនៃលក្ខណៈនេះត្រូវពិភាក្សាជាមួយលេខាធិការដ្ឋាន ។ កត់សម្គាល់ផងដែរ ប្រភេទខ្លះមានចំនួនច្រើន ដែលពិបាកណាស់ក្នុងការកត់សម្គាល់ភាពផ្សេងគ្នា នៅក្នុងទីវាល ។

**១១. ប្រភេទតំបន់ដីសើម**

បញ្ជីប្រភេទតំបន់ដីសើមបច្ចុប្បន្ន (មើលឧបសម្ព័ន្ធ២) ។ បញ្ជីប្រភេទតំបន់ដីសើម នៅក្នុងលំដាប់នៃតំបន់របស់វា នៅក្នុងតំបន់បណ្តាញផ្លូវហោះហើរ ដែលចាប់ផ្តើមដោយប្រភេទដីសើមដែលមានទំហំធំជាងគេបំផុត។

**១២. យុត្តាធិការ**

រួមបញ្ចូលដែនដីគ្រប់គ្រង ឧទាហរណ៍ រដ្ឋ/តំបន់ និងតួនាទី/ផ្នែក ដូចជា ក្រសួងកសិកម្ម /នាយកដ្ឋានបរិស្ថាន ជាដើម ។ល។

**១៣. អាជ្ញាធរគ្រប់គ្រង**

ផ្តល់ឈ្មោះ និងអាស័យដ្ឋាននៃការិយាល័យក្នុងមូលដ្ឋានរបស់ទីភ្នាក់ងារ ឬអង្គការ ដែលទទួលខុសត្រូវផ្ទាល់ ក្នុងការគ្រប់គ្រងតំបន់ដីសើម ។ បើអាច ផ្តល់ឈ្មោះ និងឋានៈនៃមន្ត្រីដែលទទួលខុសត្រូវសម្រាប់តំបន់ដីសើម ក្នុងការិយាល័យនេះ ។

**១៤. ឯកសារយោង នៃគន្លងនិទ្ទេស**

បញ្ជីនៃឯកសារយោងបច្ចេកទេសសំខាន់ៗដែលទាក់ទងតំបន់ដីសើម រួមបញ្ចូលទាំងផែនការគ្រប់គ្រង របាយការណ៍វិទ្យាសាស្ត្រសំខាន់ៗ និងគន្លងនិទ្ទេស ប្រសិនបើមាន ។ សូមចុះបញ្ជីអាស័យដ្ឋានគេហទំព័រ ដែលនៅដំណើរការ/តួនាទីមួយចំនួន ដែលបញ្ជាក់ចំពោះតំបន់ ឬភូមិសាស្ត្រតំបន់ជាក់ស្តែង និងរួមបញ្ចូលទាំង កាលបរិច្ឆេទដែលគេហទំព័រត្រូវបានធ្វើឲ្យទាន់ហេតុការណ៍ ។ នៅពេលដែលឯកសារបោះពុម្ពផ្សព្វផ្សាយ ស្តីពី តំបន់ដែលមានទំហំធំៗ អាចរកបាន ឯកសារសំខាន់បំផុត តែប៉ុណ្ណោះ ត្រូវបានដកស្រង់ ដោយឲ្យអាទិភាព ចំពោះឯកសារថ្មីៗ ដែលមានគន្លងនិទ្ទេសយ៉ាងទូលំទូលាយ ។

## ភាគ២ - អាចជ្រើសរើស

**១៥. ភូមិសាស្ត្រ នៃតំបន់**

តាមការសមរម្យ រៀបរាប់អំពីភូមិសាស្ត្រ សណ្ឋានដី ដើមកំណើត ធម្មជាតិ ឬសិប្បនិមិត្ត ជលសាស្ត្រ ប្រភេទដី គុណភាពទឹក ជំរៅទឹក ទឹកអចិន្ត្រៃយ៍ ដំណើរប្រែប្រួលកម្រិតកំពស់ទឹក ការប្រែប្រួលទឹកជោរឬនាច តំបន់ខាងក្រោមខ្សែទឹក អាកាសធាតុទូទៅ ។ល។

១៦. **ភូមិសាស្ត្រ នៃតំបន់ទីជម្រាល**

រៀបរាប់អំពីផ្ទៃក្រឡាតំបន់ ភូមិសាស្ត្រទូទៅ សណ្ឋានដី ប្រភេទដីទូទៅ និងអាកាសធាតុ (រួមបញ្ចូលប្រភេទ អាកាសធាតុ) ។

**១៧. តម្លៃជលសាស្ត្រ**

តាមការសមស្រប រៀបរាប់តួនាទី និងតម្លៃនៃតំបន់ដីសើម ក្នុងការបំពេញវិញទឹកក្រោមដី គ្រប់គ្រងទឹកជំនន់ ស្ទាក់កំណរល្បាប់ ការថែរក្សាលំនឹងតំបន់ឆ្នេរ ។ល។

**១៨. លក្ខណៈអេកូឡូស៊ីទូទៅ**

តាមការសមស្រប ផ្តល់ការរៀបរាប់បន្ថែមទៀត ស្តីពីទីជម្រកសំខាន់ៗ ប្រភេទរុក្ខជាតិ សហគមន៍រុក្ខជាតិ និងសត្វរស់នៅ នៅក្នុងតំបន់បណ្តាញផ្លូវហោះហើរ និងសេវាកម្មអេកូឡូស៊ីនៃតំបន់ និងផលប្រយោជន៍ ដែលបានពីតំបន់ទាំងនោះ ។

## ១៩.ពួករុក្ខជាតិដែលគួរកត់សម្គាល់

ផ្តល់ព័ត៌មានបន្ថែមទៀតស្តីពីប្រភេទដែលមានសារៈសំខាន់ និងមូលហេតុ ដែលកំណត់ជាប្រភេទគួរឲ្យកត់សម្គាល់ ឧទាហរណ៍ ប្រភេទ/សហគមន៍ គឺមានតែមួយគត់, ជាប្រភេទកម្រ, ជិតផុតពូជ ឬសំខាន់នៅក្នុងជីវភូមិសាស្ត្រ ។ល។ សូមកុំបញ្ចូលបញ្ជីឈ្មោះប្រភេទតាមកាយវិភាគវិទ្យា នៅទីនេះ ។ បញ្ជីឈ្មោះទាំងនោះអាចភ្ជាប់ជាព័ត៌មានបន្ថែម ជាមួយនឹងតារាងព័ត៌មាន ។

## ២០. ពួកសត្វដែលគួរកត់សម្គាល់

ផ្តល់ព័ត៌មានបន្ថែមទៀតស្តីពីប្រភេទដែលមានសារៈសំខាន់ និងមូលហេតុ ដែលកំណត់ជាប្រភេទគួរឲ្យកត់សម្គាល់ (លំអិតចំណុចសំខាន់អំពីព័ត៌មានដែលបានផ្តល់នៅចំណុចលេខ១០ ។ សូមកុំបញ្ចូលបញ្ជីឈ្មោះប្រភេទតាមកាយវិភាគវិទ្យា នៅទីនេះ ។ ទាំងនោះអាចភ្ជាប់ជាព័ត៌មានបន្ថែម ជាមួយនឹងតារាងព័ត៌មាន ។

## ២១. តម្លៃវប្បធម៌ និងសង្គម

ក) រៀបរាប់ ប្រសិនបើតំបន់នេះមានតម្លៃវប្បធម៌ និងឬសង្គមជាទូទៅ ឧទាហរណ៍ ផលិតកម្មជលផល ព្រៃឈើ សារៈសំខាន់ខាងសាសនា តំបន់បុរាណវត្ថុវិទ្យា ទំនាក់ទំនងសង្គមជាមួយតំបន់ដីសើម ។ល។ ធ្វើឲ្យឃើញឧសគ្នារវាងសារៈសំខាន់ប្រវត្តិសាស្ត្រ បុរាណវត្ថុវិទ្យា សាសនា និងតម្លៃសេដ្ឋកិច្ចសង្គមបច្ចុប្បន្ន ។

ខ) តើតំបន់នេះត្រូវគេចាត់ទុកថា មានសារៈសំខាន់ជាអន្តរជាតិសម្រាប់ តម្លៃអេកូឡូស៊ីដែលទាក់ទងបន្ថែមទៀត ឧទាហរណ៍ តម្លៃវប្បធម៌ដែលមានសារៈសំខាន់ ទោះបីជា សម្ភារៈ ឬ មិនមែនសម្ភារៈដែលផ្សារភ្ជាប់ទៅនឹងដើមកំណើតរបស់វា តួនាទីអេកូឡូស៊ី និងឬ ការអភិរក្ស?

រៀបរាប់សារៈសំខាន់នេះ តាមលំដាប់ថ្នាក់មួយ ឬច្រើន ដូចខាងក្រោម៖

១) តំបន់ដែលផ្តល់ជាគំរូនៃការប្រើប្រាស់ប្រកបដោយឈ្លាសវៃ ដែលផ្តោតលើការអនុវត្តចំណេះដឹងដែលជាប្រពៃណី និងវិធីសាស្ត្រនៃការគ្រប់គ្រង និងការប្រើប្រាស់ដែលថែរក្សាលក្ខណៈអេកូឡូស៊ីនៃតំបន់ដីសើម

២) តំបន់ដែលមានប្រពៃណី វប្បធម៌ពិសេស ឬការកត់ត្រានៃអារ្យធម៌អតីតៈ ដែលមានឥទ្ធិពលលើលក្ខណៈអេកូឡូស៊ីនៃតំបន់ដីសើម

៣) តំបន់ដែលលក្ខណៈអេកូឡូស៊ីនៃតំបន់ដីសើមពឹងផ្អែកលើអន្តរកម្មរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើម

៤) តំបន់ដែលមានតម្លៃមិនមែនទាក់ទងជាសម្ភារៈ ដូចជា តំបន់ពិសិដ្ឋ គឺមានស្ថិតនៅ និងវត្តមានរបស់វា គឺផ្សារភ្ជាប់យ៉ាងខ្លាំងជាមួយនឹងការថែរក្សាលក្ខណៈអេកូឡូស៊ីនៃតំបន់ដីសើម ។

## ២២. ការផ្តល់កម្មសិទ្ធិដីធ្លី និងភាពជាម្ចាស់

ក) នៅក្នុងតំបន់បណ្តាញផ្លូវហោះហើរ

ខ) នៅតំបន់ជុំវិញ

**២៣. ការប្រើប្រាស់ដីធ្លី (រួមទាំងទឹក)**

ក) នៅក្នុងតំបន់បណ្តាញផ្លូវហោះហើរ

ខ) នៅតំបន់ជុំវិញ ឬ តំបន់ទីជម្រាល

**២៤. កត្តា (អតីត បច្ចុប្បន្ន ឬសក្តានុពល) ដែលមានឥទ្ធិពលជាអវិជ្ជមានដល់លក្ខណៈអេកូឡូស៊ីរបស់តំបន់ រួមបញ្ចូលទាំងការផ្លាស់ប្តូរនៃការប្រើប្រាស់ដី (រួមទាំងទឹក) និងគម្រោងអភិវឌ្ឍន៍នានា**

ក) នៅក្នុងតំបន់បណ្តាញផ្លូវហោះហើរ

ខ) នៅតំបន់ជុំវិញ

**២៥. វិធានការអភិរក្សដែលបានអនុវត្ត**

ក) ធ្វើបញ្ជីចំណាត់ថ្នាក់ជាតិ និងឬ អន្តរជាតិ និងស្ថានភាពច្បាប់នៃតំបន់ការពារធម្មជាតិ រួមទាំងទំនាក់ទំនងភាពនៃព្រំប្រទល់ ជាមួយនឹងតំបន់ផ្លូវហោះហើរ ។ ជាពិសេស ប្រសិនបើ តំបន់នេះមានផ្នែកខ្លះ ឬតំបន់ទាំងមូល គឺជាតំបន់បេតិកភណ្ឌពិភពលោក និងឬ ឋបនីយជីវមណ្ឌល នៃអង្គការយូណេស្កូ ។ សូមផ្តល់ឈ្មោះនៃតំបន់ដែលស្ថិតនៅក្រោមការកំណត់តំបន់ទាំងនោះ ។

ខ) តាមការសមស្រប ចុះបញ្ជីលំដាប់ថ្នាក់តំបន់ការពារធម្មជាតិតាម IUCN (១៩៩៤) ដែលអនុវត្តសម្រាប់តំបន់ (គូសលើប្រអប់នេះ ឬប្រអប់ទាំងឡាយ តាមការសមរម្យ)

Ia ; Ib ; II ; III ; IV ; V ; VI

គ) តើមានផែនការគ្រប់គ្រងដែលបានអនុម័តជាផ្លូវការ ហើយផែនការនោះកំពុងត្រូវគេអនុវត្តឬទេ?

ឃ) រៀបរាប់អំពីការអនុវត្តការគ្រប់គ្រងបច្ចុប្បន្ន ផ្សេងៗទៀត?

**២៦. មធ្យោបាយអភិរក្សដែលបានស្នើឡើង ប៉ុន្តែមិនទាន់អនុវត្ត**

ឧទាហរណ៍ ផែនការគ្រប់គ្រង ស្ថិតនៅក្នុងការរៀបចំសំណើជាផ្លូវការ ដាក់ជាតំបន់ការពារធម្មជាតិ ជាដើម។

**២៧. បរិក្ខា និងការស្រាវជ្រាវវិទ្យាសាស្ត្រ**

ឧទាហរណ៍ រៀបរាប់លំអិតអំពីគម្រោងស្រាវជ្រាវបច្ចុប្បន្ន រួមទាំងការតាមដានជីវៈចម្រុះ ស្ថានីយ៍ស្រាវជ្រាវនៅទីវាលដែលមានស្រាប់ ។ល។

**២៨. ទំនាក់ទំនង ការអប់រំ និងសកម្មភាពផ្សព្វផ្សាយជាសាធារណៈដែលពាក់ព័ន្ធ ឬ ផលប្រយោជន៍របស់តំបន់**

ឧទាហរណ៍ មជ្ឈមណ្ឌលទេសចរណ៍ ទីកន្លែងអង្កេត និងផ្លូវដើរធម្មជាតិ សៀវភៅព័ត៌មាន បរិក្ខាសម្រាប់ការទស្សនារបស់សិស្សសាលា ។ល។

**២៩. ទេសចរណ៍ និងការកំសាន្តបច្ចុប្បន្ន**

ធ្វើការរៀបរាប់ ប្រសិនបើ តំបន់ដីសើមត្រូវប្រើប្រាស់ជាកន្លែងទេសចរណ៍/ការកំសាន្ត, បញ្ជាក់អំពីប្រភេទ និងប្រពលភាព/ផលប៉ះពាល់របស់វា ។

## ឧបសម្ព័ន្ធ១ : លក្ខណៈវិនិច្ឆ័យសម្រាប់បញ្ចូលតំបន់ក្នុងបណ្ដាញតំបន់ផ្លូវហោះហើរ

(ដកស្រង់ចេញពីអត្ថបទភាពជាដៃគូ)

ដើម្បីយកចិត្តទុកដាក់ចំពោះការបញ្ចូលក្នុងបណ្ដាញតំបន់ផ្លូវហោះហើរ ភាពជាដៃគូបានអនុម័តលើលក្ខណៈវិនិច្ឆ័យដូចតទៅ៖

ក) អនុសញ្ញាស្ដីពីតំបន់ដីសើម (រ៉ាមសារ ប្រទេសអ៊ីរ៉ង់ឆ្នាំ១៩៧១) លក្ខណៈវិនិច្ឆ័យ សម្រាប់តំបន់ដែលមានសារៈសំខាន់ជាអន្តរជាតិសម្រាប់សត្វស្លាបទឹកទេសន្តរប្រវេសន៍ គឺ៖

លក្ខណៈវិនិច្ឆ័យ ២៖ តំបន់ដីសើមមួយ គួរត្រូវចាត់ទុកថាមានសារៈសំខាន់ជាអន្តរជាតិ ប្រសិនបើវាទ្រទ្រង់ប្រភេទជិតផុតពូជបំផុត ប្រភេទជិតផុតពូជ ប្រភេទងាយរងគ្រោះ ឬសហគមន៍ដែលអេកូឡូស៊ីរងការគម្រាមកម្ហែង ។

លក្ខណៈវិនិច្ឆ័យ ៥៖ តំបន់ដីសើមមួយ គួរត្រូវចាត់ទុកថា មានសារៈសំខាន់ជាអន្តរជាតិ ប្រសិនបើវាទ្រទ្រង់ជាទៀងទាត់នូវសត្វស្លាបទឹកចំនួន ២០.០០០ ឬ ច្រើនជាងនេះ

លក្ខណៈវិនិច្ឆ័យ ៦៖ តំបន់ដីសើមមួយ គួរត្រូវចាត់ទុកថា មានសារៈសំខាន់ជាអន្តរជាតិ ប្រសិនបើវាទ្រទ្រង់ជាទៀងទាត់ ១%នៃសត្វស្លាបទឹក នៅក្នុងចំនួនសរុបនៃប្រភេទមួយ ឬអនុប្រភេទមួយ ។

ខ) លក្ខណៈវិនិច្ឆ័យសម្រាប់តំបន់សំចត ដូចដែលបានអនុវត្ត នៅក្រោមយុទ្ធសាស្ត្រអភិរក្សសត្វស្លាបទឹកដែលធ្វើទេសន្តរប្រវេសន៍អាស៊ី-ប៉ាស៊ីហ្វិច ។ នោះ គឺ៖

១) តំបន់សំចត គួរត្រូវចាត់ទុកថាមានសារៈសំខាន់ជាអន្តរជាតិ ប្រសិនបើ វាទ្រទ្រង់ជាទៀងទាត់ ០,២៥% នៃសត្វស្លាបទឹក នៅក្នុងចំនួនសរុប នៃប្រភេទមួយ ឬ អនុប្រភេទនៃសត្វស្លាបទឹកដែលធ្វើទេសន្តរប្រវេសន៍

២) តំបន់សំចត គួរត្រូវចាត់ទុកថា មានសារៈសំខាន់ជាអន្តរជាតិ ប្រសិនបើ វាទ្រទ្រង់ជាទៀងទាត់សត្វស្លាបទឹកចំនួន ៥.០០០ ឬ ច្រើនជាងនេះ នៅពេលមួយ ក្នុងកំឡុងពេលដែលធ្វើទេសន្តរប្រវេសន៍ ។

គ) ក្នុងកាលៈទេសៈពិសេស តំបន់មួយអាចត្រូវបានតែងតាំង បើសិនវាទ្រទ្រង់សត្វស្លាបទឹកដែលធ្វើទេសន្តរប្រវេសន៍ នៅកម្រិតមួយ ឬ វគ្គនៃវដ្តជីវិតរបស់ពួកវា ដែលសំខាន់ចំពោះការថែរក្សា នៃចំនួនសត្វស្លាបទឹក នៅក្នុងផ្លូវហោះហើរ ។ ការផ្ទៀងផ្ទាត់នៃការតែងតាំងនេះ នឹងត្រូវយកចិត្តទុកដាក់អនុវត្ត ដោយភាពជាដៃគូ ដោយផ្អែកលើពីមួយករណី ទៅមួយករណីទៀត ។

## ឧបសម្ព័ន្ធ ២: ប្រព័ន្ធចំណាត់ថ្នាក់រ៉ាមសារ សម្រាប់ប្រភេទដីសើម

លេខសម្គាល់ (Code) គឺផ្អែកលើប្រព័ន្ធចំណាត់ថ្នាក់រ៉ាមសារ សម្រាប់ប្រភេទតំបន់ដីសើម ដែលបានអនុម័តដោយអនុសាសន៍ ៤.៧ និងបានកែប្រែ ដោយសេចក្ដីសម្រេច VI. ៥ និងVII.១១ នៃសន្និសិទរបស់ដៃគូ

ជាប់កិច្ចសន្យា ។ លំដាប់ថ្នាក់ដែលបានចុះបញ្ជី តទៅនេះ គឺ ដើម្បីផ្តល់យន្តការទូលាយមួយ សម្រាប់ជួយការធ្វើអត្តសញ្ញាណកម្ម នៃទីជម្រកតំបន់ដីសើមសំខាន់ៗ ដែលតំណាងឲ្យតំបន់នីមួយៗ ។

ដើម្បីជួយក្នុងការធ្វើអត្តសញ្ញាណកម្ម នៃប្រភេទតំបន់ដីសើមត្រឹមត្រូវ សម្រាប់ចុះបញ្ជីក្នុងផ្នែកទី១៩ នៃតារាងព័ត៌មានរ៉ាមសារ លេខាធិការដ្ឋានផ្តល់ការរៀបចំបញ្ជីសម្រាប់តំបន់ដីសើមសមុទ្រ/តំបន់ឆ្នេរ និងតំបន់ដីសើមទឹកសាបដែលមានចរិកលក្ខណៈមួយចំនួន នៃប្រភេទតំបន់ដីសើមនីមួយៗ ដូចខាងក្រោម ៖

## *តំបន់ដីសើមសមុទ្រ/តំបន់ឆ្នេរ*

A-- **តំបន់ទឹកសមុទ្រអចិន្ត្រៃយ៍ដែលមានជំរៅរាក់**៖ ក្នុងករណីជាច្រើន មានជំរៅតិចជាង៦ម៉ែត្រ នៅពេលទឹកនាច៖ រួមបញ្ចូលទាំង ឈូងសមុទ្រ និងដៃសមុទ្រ

B-- **ទីវាលលិចទឹកសមុទ្រជោរនាច** ៖ រួមទាំង វាលស្មៅសមុទ្រ ទីទំនាបសមុទ្រតំបន់ត្រូពិច

C-- **តំបន់ផ្កាថ្ម**

D-- **តំបន់ឆ្នេរថ្ម** ៖ រួមបញ្ចូលទាំង កោះថ្មក្នុងសមុទ្រ ប្រាំងថ្មចោទ

E-- **ឆ្នេរខ្សាច់ ឆ្នេរថ្ម ឬឆ្នេរគ្រោះ** ៖ រួមបញ្ចូលទាំងតំបន់ជួរខ្សាច់ ឆកសមុទ្រ និងកោះខ្សាច់ រួមទាំងប្រព័ន្ធផ្នូកខ្សាច់ និងពុំនូកខ្សាច់ដែលសើម ។

F-- **ទឹកដៃសមុទ្រ**៖ ទឹកអចិន្ត្រៃយ៍ នៃដៃសមុទ្រ និងប្រព័ន្ធដៃសមុទ្រ

G-- **តំបន់វាលភក់ វាលខ្សាច់ទឹកជោរនាច និងស្រែអំបិល**

H-- **វាលភក់ទឹកជោរនាច**៖ រួមបញ្ចូលទាំង វាលភក់ទឹកប្រៃ វាលស្មៅទឹកប្រៃ តំបន់ដែលប្រៃ វាល់ភក់ទឹកប្រៃដែលជោរខ្លាំង ដែលរួមមានតំបន់ទឹកភ្លាវជោរនាច និងវាលភក់ទឹកសាប ។

I-- **ទីវាលលិចទឹកសមុទ្រជោរនាច** ៖ រួមមានវាលភក់ព្រៃកោងកាង វាលភក់ nipahនិងព្រៃវាលភក់ទឹកសាបដែលទឹកជោរនាច ។

J-- **អន្លង់តំបន់ឆ្នេរទឹកប្រៃ/ទឹកភ្លាវ** ៖ ចាប់ពីអន្លង់ទឹកភ្លាវទៅទឹកប្រៃ ដោយយ៉ាងហោចណាស់មានការទំនាក់ទំនងជាមួយនឹងសមុទ្រ ។

K-- **អន្លង់ទឹកសាបតំបន់ឆ្នេរ**៖ រួមមានអន្លង់ដៃទន្លេទឹកសាប ។

ZK(a)- **ប្រព័ន្ធជលសាស្ត្រផ្សេងៗ និង រណ្តៅ (Karst)** ៖ តំបន់សមុទ្រ/តំបន់ឆ្នេរ

## *តំបន់ដីសើមទឹកសាប*

L -- **ដៃទន្លេអចិន្ត្រៃយ៍**

M -- **ទន្លេ /ស្ទឹង/ ព្រែក** រួមទាំងទឹកធ្លាក់

N -- **ទន្លេ /ស្ទឹង/ ព្រែកដែលតាមរដូវកាល ឬដែលសម្រាប់ស្រោចស្រព**

O -- **បឹងទឹកសាបអចិន្ត្រៃយ៍ (ធំជាង៨ហិកតា)** រួមទាំង បឹងដែលមានរង្វង់ធំៗ

P -- **បឹងទឹកសាបតាមរដូវកាល/ដែលកើតមានឡើងមិនទៀងទាត់/ មិនអចិន្ត្រៃយ៍**

R -- **បឹង និងទីវាលទឹកប្រៃ/ទឹកភ្លាវ ឬអាលកាឡាំង**

Sp-- **វាលភក់/អន្លង់ ទឹកប្រៃ/ទឹកភ្លាវ ឬអាលកាឡាំងអចិន្ត្រៃយ៍**

Tp -- **អន្លង់/វាលភក់ទឹកសាបអចិន្ត្រៃយ៍៖** ត្រពាំង (តូចជាង៨ហិកតា)វាលភក់ និងវាលល្បាប់ ដែលមានដីអសរីរាង្គ ដោយមានរុក្ខជាតិនៅជុំវិញមាត់ទឹក ដែលយ៉ាងហោចណាស់ ភាគច្រើន នៅក្នុងរដូវលូតលាស់ ។

Ts -- **អន្លង់/វាលភក់ទឹកសាបតាមរដូវកាល/ដែលកើតមានឡើងមិនទៀងទាត់ /ដែលមាននៅលើដីអសរីរាង្គ៖** រួមទាំង ប្រលាយភក់ រូងក្រោមដី វាលស្មៅលិចទឹកតាមរដូវ វាលភក់ដែលមានស្មៅត្រែង

U -- **តំបន់ដីមោគដែលគ្មានព្រៃ** ៖ រួមទាំងតំបន់ព្រៃល្បាស់ វាលលំហរ វាលភក់ ទីទំនាប់

Va -- **តំបន់ដីសើមភ្នំអ័ល្ប** ៖ រួមទាំង តំបន់វាលស្មៅភ្នំអ័ល្ប ទឹកមិនអចិន្ត្រៃយ៍ដែលបានពីការរលាយទឹកកក ។

Vt -- **តំបន់ដីសើមទុងត្រា៖** រួមទាំងអន្លង់ទុងត្រា ទឹកមិនអចិន្ត្រៃយ៍ដែលបានពីការរលាយទឹកកក ។

W -- **តំបន់ដីសើមដែលព្រៃល្បាស់ដុះលប់** ៖ វាលភក់ព្រៃល្បាស់ វាលទំនាបទឹកសាបដែលគ្របដណ្តប់ដោយព្រៃល្បាស់ តំបន់ព្រៃស្អុក ព្រៃគម្លោតញឹកដែលនៅលើដីអសរីរាង្គ ។

Xf -- **តំបន់ទឹកសាប, តំបន់ដីសើមដែលគ្របបណ្តប់ដោយដើមឈើ៖** រួមទាំង ព្រៃលិចទឹកតាមរដូវ ព្រៃវាលភក់ទឹកសាប ព្រៃវាលភក់នៅលើដីអសរីរាង្គ ។

Xp -- **ដីមោគដែលមានព្រៃ៖** ព្រៃវាលភក់អំពុករុក្ខជាតិ

Y -- **ស្ទ្រឹងទឹកសាប,** អូស៊ីស(Oases)

Zg -- **តំបន់ដីសើមដែលកើតមានឡើងដោយកំដៅក្នុងផែនដី**

Zk(b) -- **ប្រព័ន្ធទឹកក្រោមដីផ្សេងៗ និងចង្អូរ Karst** ៖ តំបន់ដែលនៅឆ្ងាយពីសមុទ្រ

ចំណាំ៖ “ទំនាបលិចទឹក” គឺជាពាក្យទូលំទូលាយដែលប្រើប្រាស់ ដើម្បីយោងទៅលើប្រភេទតំបន់ដីសើមមួយ ឬច្រើន ដែលអាចរួមបញ្ចូល ក្នុងឧទាហរណ៍ ចាប់ពី R, Ss, Ts, W, Xf, Xp, ឬ ប្រភេទតំបន់ដីសើមដទៃទៀត ។ ឧទាហរណ៍ខ្លះនៃតំបន់ដីសើមទំនាបលិចទឹក គឺវាលស្មៅលិចទឹកតាមរដូវ (រួមទាំង វាលស្មៅតំបន់សើមធម្មជាតិ) តំបន់ព្រៃល្បាស់ តំបន់ព្រៃស្អុក និងតំបន់ព្រៃ ។ នៅទីនេះ តំបន់ដីសើមទំនាប់លិចទឹក គឺមិនត្រូវបានចុះបញ្ជីជាតំបន់ដីសើមមួយជាក់លាក់ទេ ។

*តំបន់ដីសើមដែលបង្កើតដោយមនុស្ស*

១-- **ស្រះចិញ្ចឹមត្រី/បង្គា**

២-- **ស្រះ** ៖ រួមទាំង ស្រះចិញ្ចឹម ស្រះស្អុក អាងតូចៗ (ជាទូទៅតូចជាង ៨ ហិកតា)

៣-- **តំបន់ដីស្រោចស្រព** ៖ រួមទាំង ប្រឡាយស្រោចស្រព និងវាលស្រែ

៤-- **តំបន់ដីកសិកម្មលិចទឹកតាមរដូវ** (រួមទាំងវាលស្មៅដែលត្រូវគេគ្រប់គ្រង និងវាលស្មៅសត្វស៊ី ឬ វាលស្មៅចិញ្ចឹមសត្វ

៥-- **តំបន់អាជីវកម្មអំបិល** ៖ ស្រែអំបិល, តំបន់ដែលមានអំបិល ។ល។

៦-- **តំបន់ស្តុកទឹក** ៖ អាងទឹក/របាំងទឹក/ទំនប់ទឹក/ការបង្ខាំង ជាទូទៅមានទំហំលើស៨ហិកតា)

៧-- **ក្រហូងដី** ៖ អន្លុងដីឥដ្ឋ រណ្តៅដីក អណ្តូងរ៉ែ

៨-- **តំបន់ប្រព្រឹត្តកម្មទឹកសំណល់** ៖ វាលទឹកសំអុយ ស្រះស្តុក អាងប្រព្រឹត្តកម្មអុកស៊ីសែន ។ល។

៩-- **ព្រែកជីក និងប្រឡាយបង្ហូរ, ប្រឡាយភ្លោះ**

Zk(c)- **ប្រព័ន្ធទឹកក្រោមដីផ្សេងៗ និងចង្ហូរ Karst** ៖ មនុស្សធ្វើ